# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
អគ្គនាយកដ្ឋានកសិកម្ម

លេខ ១១៣៤ អ.ន.ក

ថ្ងៃ ពុធ ១០កើត ខែ បឋមាសាឍ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ២០១៨

**សូមគោរពជូន**
**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**កម្មវត្ថុ៖** របាយការណ៍ស្តីពីសកម្មភាពអនុវត្តការងារប្រចាំខែឧសភា ឆ្នាំ២០១៨ របស់អគ្គនាយកដ្ឋានកសិកម្ម។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមអនុញ្ញាតរាយការណ៍ជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបនូវលទ្ធផលអនុវត្តសកម្មភាពការងាររបស់អគ្គនាយកដ្ឋានកសិកម្មប្រចាំខែឧសភា ឆ្នាំ២០១៨ មានដូចខាងក្រោម៖

I. **លទ្ធផលបង្កបង្កើនផលកសិកម្មរដូវវស្សាឆ្នាំ២០១៧-២០១៨**(គិតត្រឹមថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៨)

**១. ដំណាំស្រូវ** : ផ្ទៃដីស្ទូងព្រោះសរុបអនុវត្តបានចំនួន ៦៥៦.៤៤៤ ហ.ត ស្មើនឹង២៦,១១% នៃផែនការចំនួន ២.៥១៣.៨៩៥ ហ.ត លឿនជាងឆ្នាំមុនចំនួន ២៦៨.៨៨០ ហ.ត

- ការងារភ្ជួររាស់ដី : ផ្ទៃដីភ្ជួររាស់សរុបអនុវត្តបានចំនួន ៨០៩.៥១៧ហ.ត លឿនជាងឆ្នាំមុនចំនួន ១៨១.៨៥២ ហ.ត ក្នុងនោះផ្ទៃដីភ្ជួររាស់ដោយគ្រឿងយន្តចំនួន ៧៩៨.៨៥៧ ហ.ត ស្មើនឹង៩៨,៦៨% នៃផ្ទៃដីភ្ជួររាស់សរុប
- ផ្ទៃដីសាបសរុប : ១.៣៣៨ ហ.ត លឿនជាងឆ្នាំមុនចំនួន ៥៥៩ ហ.ត។







*ក្រាហ្វិក៖ ស្ថិតិផ្ទៃដីភ្ជួររាស់ និងដាំដុះស្រូវរដូវវស្សាពីឆ្នាំ២០១៤-២០១៨ គិតត្រឹម ចុងខែឧសភា នៃឆ្នាំ*

តាមក្រាហ្វិកខាងលើបង្ហាញថា ក្នុងរយៈពេល៥ឆ្នាំដូចគ្នាគិតត្រឹមចុងខែឧសភា ផ្ទៃដីភ្ជួររាស់រដូវវស្សាឆ្នាំ២០១៨ មានចំនួនច្រើនជាងបណ្តាឆ្នាំមុនៗ ។ ដោយឡែកការងារដាំដុះស្រូវរដូវវស្សាឆ្នាំ២០១៨នេះ មានចំនួនច្រើនជាងបណ្តាឆ្នាំមុនៗ បើប្រៀបធៀបរយៈពេលដូចគ្នា៥ឆ្នាំចុងក្រោយ។

**២. ដំណាំរួមផ្សំ** : អនុវត្តបានចំនួន ១០.៦៧៨ ហ.ត លឿនជាងឆ្នាំមុនចំនួន ៩៦ ហ.ត។

**៣. ដំណាំឧស្សាហកម្ម** : អនុវត្តបានចំនួន ៣៤២.២១៩ ហ.ត លឿនជាងឆ្នាំមុនចំនួន ៨៤.២១៤ ហ.ត។



អាសយដ្ឋានលេខ: ៥៤បេ/៤៩អេហ្វ ផ្លូវលេខ ៣៩៥-៦៥៦ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ទូរស័ព្ទលេខ:(០២៣) ៨៨៣ ៤២៧ ទូរសារលេខ:(០២៣) ៨៨៣ ៤២៧
Address # 54B/49F, Street 395-656, Sangkat Toeuk Laak 3, Khan Tuol Kok, Phnom Penh. Cambodia, Phone : (023) 883 427, Fax : (023) 883 427